អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
ការិយាល័យសហព្រះរាជអាជ្ញា
Extraordinary Chambers in the Courts of Cambodia
Office of the Co-Prosecutors

ភ្នំពេញថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៨

# សេចក្តីថ្លែងការណ៍របស់ការិយាល័យសហព្រះរាជអាជ្ញា

នៅថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០០៨ ដោយអនុលោមតាមវិធានផ្ទៃក្នុង៧១(២) នៃតុលាការនេះ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ សេចក្តីថ្លែងអំពីការខ្វែងគំនិតគ្នារវាងសហព្រះរាជអាជ្ញាទាំងពីរ រួចបញ្ជូនទៅការិយាល័យរដ្ឋបាលដើម្បីទទួលការសម្រេចសេចក្តីពីសំណាក់ អង្គបុរេជំនុំជម្រះ។ ការខ្វែងគំនិតគ្នានេះ ស្ថិតនៅលើភាពសមស្របនៃការបើកកិច្ចស៊ើបអង្កេតថ្មីតាមផ្លូវតុលាការទៅលើឧក្រិដ្ឋកម្មទាំងឡាយ ដែលប្រព្រឹត្តឡើងនៅតាមបណ្តាទីតាំងនានាទូទាំងប្រទេសកម្ពុជាដោយជនមួយចំនួនដែលត្រូវបានចាត់ទុកជាមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហម ឬជនដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មក្រោមរបបនោះ។។ ការិយាល័យរដ្ឋបាលបានទទួល និងជូនដំណឹងដល់អង្គបុរេជំនុំជម្រះអំពីការខ្វែងគំនិតគ្នានេះដើម្បីធ្វើការសម្រេចសេចក្តី។ ការិយាល័យរដ្ឋបាលបានបញ្ជូនសំណុំរឿងនេះទៅអង្គបុរេជំនុំជម្រះ។

កិច្ចស៊ើបអង្កេតបឋមរបស់សហព្រះរាជអាជ្ញា និង ការសម្រេចសេចក្តីរបស់អង្គបុរេជំនុំជម្រះទៅលើវិវាទរវាងសហព្រះរាជអាជ្ញាទាំងពីរ តាមច្បាប់ គឺជាការសម្ងាត់ ។ ប្រការនេះគឺឈរលើគោលការណ៍សច្ចធារណ៍នៃនិរទោស ការការពារជនរងគ្រោះ និង សាក្សី និងជាពិសេសបំផុតគឺការពារបូរណភាពនៃដំណើរការស៊ើបអង្កេត ។

សហព្រះរាជអាជ្ញាត្រូវតែខិតខំពុះពារសម្រេចឱ្យបាននូវការព្រមព្រៀងគ្នាមួយពេញអំឡុងនៃដំណើរការទាំងមូលនៃការសម្រេច តាមផ្លូវតុលាការទៅលើការខ្វែងគំនិតគ្នានេះ។ ដោយមិនគិតអំពីលទ្ធផលនៃការខ្វែងគំនិតគ្នានេះ សហព្រះរាជអាជ្ញាបាន និងងបន្តធ្វើការជាមួយគ្នាគ្រប់សំណុំរឿងទាំងអស់ដើម្បីធានាឱ្យប្រាកដថា យុត្តិធម៌ពិតជាបានផ្តល់ដល់ជនរងគ្រោះនៃរបបខ្មែរក្រហម ៕

-ចប់-